# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..០៥...ស.សរ

## សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃការខូចខាតលើអាគារនិងទ្រព្យសម្បត្តិរបស់ស្ថានទូតនៃព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :**

- បង្កើតគណៈកម្មការវាយតម្លៃការខូចខាតលើអាគារ និងទ្រព្យសម្បត្តិរបស់ស្ថានទូតនៃព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបាត់បង់ និងខូចខាតក្នុងឧបទ្ទវហេតុ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៣ នៅក្នុងរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ប្រាក់ | សុខុន | ប្រធាន |
| ២- | លោកជំទាវ | ស៊ុន | សាភឿង | អនុប្រធាន |
| ៣- | ឯកឧត្តម | ឡូ | ណារ៉ាត | សមាជិក |
| ៤- | ឯកឧត្តម | ញាណ | ឡេង | សមាជិក |
| ៥- | ឯកឧត្តម | នុប | នៃស៊ីតូ | សមាជិក |
| ៦- | ឧត្តមសេនីយ៍ទោ | នុល | គឿន | សមាជិក |
| ៧- | លោក | ម៉ប់ | សារិន | សមាជិក |

**ប្រការ ២ :**

- គណៈកម្មការនេះមានភារកិច្ចសិក្សាវាយតំលៃការខូចខាតលើអាគារ និងទ្រព្យសម្បត្តិរបស់ស្ថានទូត និងមន្ត្រី បុគ្គលិកស្ថានទូត នៃព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាច្រកកម្ពុជា ដែល បានខូចខាត និងបាត់បង់ក្នុងឧបទ្ទវហេតុ នាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៣ រួចរាយការណ៍ជូន សម្តេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៣ :**

- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីលើលិខិតផ្លូវការ ។

**ប្រការ ៤ :**

- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សាលាក្រុងភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *ឯកសារ- កាលប្បវត្តិ*